**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ**
**មន្ទីរកសិកម្មខេត្តស្វាយរៀង**

លេខ ..........ក.ស.ក/ស្វរ ស្វាយរៀង, ថ្ងៃទី ខែ ឆ្នាំ ២០១៦

**មន្ទីរកសិកម្មខេត្ត**
**<u>គោរពជូន</u>**
**ឯកឧត្តម អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការជម្រុញចលនា**
**ភូមិ ១ ផលិតផល ១ ខេត្តស្វាយរៀង**

**ជាទីគោរព** !

**កម្មវត្ថុ:** ស្តីពីរបាយការណ៍លទ្ធផលសកម្មភាពសហគមន៍កសិកម្មចូលរួមក្នុងការអនុវត្តន៍ យុទ្ធសាស្រ្ត ភូមិ ១ ផលិតផល១ របស់ខេត្តស្វាយរៀង ប្រចាំឆមាសទី ១ ឆ្នាំ២០១៦ និងទិសដៅ ឆមាសទី២ ឆ្នាំ ២០១៦

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើខ្ញុំបាទសូមអនុញ្ញាតិធ្វើសេចក្តីរាយការណ៍ជូនឯកឧត្តម អំពីលទ្ធផលសកម្មភាពសហគមន៍កសិកម្មចូលរួមក្នុងការអនុវត្តន៍យុទ្ធសាស្រ្ត ភូមិ១ ផលិតផល ១ របស់ខេត្តស្វាយរៀង ប្រចាំឆមាសទី ១ ដូចតទៅ ៖

**សកម្មភាពទី ១ :**

- បង្កើតឡើងនូវរចនាសម្ព័ន្ធប្រព័ន្ធផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ថ្នាក់ ខេត្ត និង ថ្នាក់ស្រុក
- ចងក្រងនិងបង្កើតសហគមន៍កសិកម្មបានចំនួន ០៨ សហគមន៍សរុបទូទាំងខេត្តមាន ៣៧ សហគមន៍
- ចងក្រងនិងបង្កើតក្រុមកសិកម្មចិញ្ចឹមមាន់ តាមវិធីសាស្រ្តជីវសុវត្ថិភាពចំនួន ១៩២ ក្រុម ក្នុងស្រុកគោលដៅទាំង 0៤ របស់គម្រោង PADEE

ធ្វើការសម្របសម្រួល ជាមួយអង្គការជាតិ អន្តរជាតិ ផ្នែកឯកជនដើម្បីលើកកម្ពស់ខ្សែសង្វាក់ផលិតកម្ម និងទីផ្សារបាន០១លើកវត្តមានចូលរួម ២៦៣នាក់ ។

**សកម្មភាពទី ២:**

សហការណ៍ជាមួយដៃគូរ និងអង្គភាពពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍន៍ដើម្បីពង្រឹង ពង្រីកសមត្ថភាព ក្នុងប្រតិបត្តិការធ្វើជំនួញរបស់សហគមន៍ទាំង ៤

+ សហគមន៍កសិកម្មចិញ្ចឹមជ្រូក

+ សហគមន៍កសិកម្មផ្គត់ផ្គង់បន្លែសរីរាង្គ

+ សហគមន៍កសិកម្មផលិតស្រូវ

+ សហគមន៍ផលិតកម្មប្រេងប្រចាក់

**សកម្មភាពទី៣**

បន្តការសិក្សាស្រាវជ្រាវ ប្រភេទផលិតផល ចំបងៗដើម្បីអភិវឌ្ឍន៍ ភូមិ១ ផលិតផល១ឲ្យប្រសើរឡើង

១ ផលិតផលស្រូវ (ផ្ការំដួលនិងស្រូវស្មាច់ )

២ ផលិតផលបន្លែសរីរាង្គ

៣ ផលិតផលសត្វ (គោ ជ្រូក មាន់ )

៤ ផលិតផលប្រេងប្រចាក់ (កែច្នៃពាក់កណ្តាលសម្រេច)

៥ ផលិតផលអំពៅស្ករ (វត្ថុធាតុដើម)

៦ ផលិតផលដំឡូងមី ( វត្ថុធាតុដើម)

**សកម្មភាពទី៤**

បន្តផ្សព្វផ្សាយតាមគ្រប់មធ្យោបាយ ដល់គ្រប់ស្ថាប័ន អង្គភាព សហគមន៍កសិកម្ម និងដៃគូអភិវឌ្ឍន៍ វិស័យឯកជន ដើម្បីលើកម្ពស់ ផលិតកម្ម បង្កើនការងារ បង្កើនប្រាក់ចំណូល និង ថែរក្សាបរិស្ថាន ។

ផ្សព្វផ្សាយតាមរយៈវគ្គអប់រំខ្លី បាន ២៨០ លើក វគ្គមានចូលរួម ៤,១៥០ នាក់ ក្នុងនោះ

១ ប្រព័ន្ធកសិកម្មចម្រុះ ១៤ វគ្គ វគ្គមាន ៤២០ នាក់

២ សន្និបាតសហគមន៍កសិកម្ម ២២លើក ២២ សហគមន៍កសិកម្ម វគ្គមានចូលរួម ១៨៧០ នាក់

៣ ប្រជុំផ្សព្វផ្សាយសារៈប្រយោជន៍ឡជីវឧស្ម័ន ៥២ លើក វគ្គមានចូលរួម ៨៧៥នាក់

៤ វគ្គបណ្តុះបណ្តាលចិញ្ចឹមមាន់ជីវសុវត្ថិភាពចំនួន ១៩២លើក វគ្គមមានចូលរួម ៩៨៥ នាក់

**សកម្មភាពទី ៥**

ប្រមូលព័ត៌មានអំពីសក្តានុពលផលិតសំខាន់ៗដើម្បីធ្វើផែនទីផលិតផល(ភូមិ ១ ផលិតផល១) រួមមាន:

- ផលិតផលស្រូវ (ផ្ការំដួល ស្រូវស្មាច់)
- ផលិតផលបន្លែសរីរាង្គ

- ផលិតផលសត្វ គោ ជ្រូក មាន់
- ផលិតផលអំពៅ (វត្ថុធាតុដើម)
- ផលិតផលដំឡូងមី(វត្ថុធាតុដើម)
- ផលិតផលប្រេងប្រចាក់(ផលិតផលពាក់កណ្តាលសម្រេច)
- ផលិតផលឡជីវឧស្ម័ន

**សកម្មភាពទី ៦**

ដំណើរការអភិវឌ្ឍន៍ផលិតផល (បរិមាណនិងគុណភាព) ជាជំហ៊ានៗ

១ សហគមន៍កសិកម្មចិញ្ចឹមជ្រូកផ្គត់ផ្គង់ជ្រូក(ចំនួន ៥,៧៨៨ ក្បាល ស្មើ ៥២១ តោន )

២ សហគមន៍កសិកម្មចំនួន ០៧ ផលិតស្រូវ

ស្រូវផ្ការំដួល បរិមាណ ៤,០០០ តោន - ៥,០០០ តោន

ស្រូវស្មាច់ បរិមាណ ១,០០០ តោន - ១,៥០០ តោន ក្នុងឆ្នាំ ២០១៥

៣ សហគមន៍កសិកម្មចំនួន ០៣ ផលិតបន្លែសរីរាង្គផ្គត់ផ្គង់ទីផ្សារ

- ផ្សារទំនើប (AEON) ភ្នំពេញ បរិមាណ ១២,៣១៣ គ.ក្រ (រយៈពេល០៦ខែ)
- ទីផ្សារក្នុង និងក្រៅខេត្ត បរិមាណ ៥៥,៥៦១ គ.ក្រ(ក្រុងស្វាយរៀង បាវិត ភ្នំពេញ)

៤ ផលិតផល(ប្រេងប្រចាក់) បរិមាណ ៥,៩៥០ លីត្រ (ទីផ្សារវៀតណាម)

៥ ផលិតផលឡជីវឧស្ម័ន ចំនួន១៦១ កន្លែង ( រយៈពេល០៦ខែ)

ដោយឡែកសហគមន៍អំពៅស្ករ ដំឡូងមី (វត្ថុធាតុដើម) កំពុងដំណើរការចងក្រង (ផលិតកម្មតាមកិច្ចសន្យា) ។

**សកម្មភាពទី ៧**

ការគ្រប់គ្រង អាជីវកម្ម ការជម្រុញអភិវឌ្ឍន៍ទីផ្សារ

- បានសហការជាមួយអង្គការ SNV បើកវគ្គបណ្តុះបណ្តាល អំពីការលើកកម្ពស់ខ្សែសង្វាក់ផលិតកម្ម តម្លៃ និងទីផ្សារ បាន ០១ វគ្គ មានការចូលរួមពីតួអង្គសំខាន់ៗ ចំនួន ៥២ នាក់
- បើកវគ្គបណ្តុះបណ្តាលការគ្រប់គ្រង អាជីវកម្ម (ជំនួញ)ដល់តំណាងសហគមន៍កសិកម្មទូទាំងខេត្ត ចំនួន ០១ វគ្គ វគ្គមានចូលរួម ១១១ នាក់ គាំទ្រពី (BPAC/ JICA) ។
- ចូលរួមពិព័ណ៌ផលិតផល នៅសាកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន១ លើក

**សកម្មភាពទី ៨**

ក្នុងឆមាសទី១ នេះអង្គភាពបានធ្វើការគៀងគរ ថវិការ ពីដៃគូនានា និងផ្នែកឯកជន ដំណើរការប្រារព្ធវេទិការក្រោមប្រធានបទ សហគមន៍កសិកម្ម និងទីផ្សារ បាន០១ លើក វគ្គមានចូលរួម ២៦៣ ។

**ការលំបាក**

+ ការយល់ដឹងពអំពីទស្សនៈទាន ភូមិ១ផលិតផល១ នៅមានកម្រិត
+ កង្វះថវិការគាំទ្រ សកម្មភាព
+ យន្តការកិច្ចដំណើរការ របស់គណៈកម្មាធិការជម្រុញចលនាមិនទាន់ដំណើរការបានល្អ
+ ការប្តូរមុខដំណាំ ដែលមានសក្តានុពល

**ទិសដៅបន្ត**

១ បន្តផ្សព្វផ្សាយឲ្យបានទូលំទូលាយលើទស្សនៈទានភូមិ ១ ផលិតផល១

២ ពង្រឹងកិច្ចដំណើរការប្រព័ន្ធ ផ្សព្វផ្សាយ កសិកម្មខេត្ត ស្រុក

៣ លើកកម្ពស់ ប្រសិទ្ធភាព នៃការគ្រប់គ្រងអាជីវកម្ម របស់សហគមន៍កសិកម្ម (ខ្សែសង្វាក់ ផលិតកម្ម និងទីផ្សារ)

៤ ស្វែងរកធនធានគាំទ្រ (បច្ចេកទេស ហិរញ្ញវត្ថុ)

៥ រៀបចំផែនទីភូមិ ១ ផលិតផល១

៦រៀបចំផែនការអភិរក្ស និង អភិវឌ្ឍន៍ ផលិតផលមានសក្តានុពលខ្ពស់ ។

សេចក្តីដូចបានជម្រាបជូនខាងលើសូម**ឯកឧត្តម** មេត្តាជ្រាបជាពត៌មានដ៏ខ្ពង់ខ្ពស់ ដោយអនុគ្រោះ ។

**ប្រធានមន្ទីរ**

# កម្មវិធីទស្សនៈកិច្ចសកម្មភាពភូមិ និងផលិតផល ភូមិ ១ ផលិតផល ១
# ថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០១៦

| ពេលវេលា | បរិយាយសកម្មភាព | ទីកន្លែង | ផ្សេងៗ |
|---|---|---|---|
| 11:30- 12:30 | ទស្សនាកាធ្វើចំណាត់ថ្នាក់ វេចខ្ចប់បន្លែផ្គត់ផ្គង់ផ្សារ ទំនើប AEON Mall នៅភ្នំពេញ | សហគមន៍ផ្គត់ផ្គង់ កសិផលស្វាយរៀង (SAC) | |
| 12:30 – 14:00 | ពិសារអាហារថ្ងៃត្រង់ | | |
| 14: 00 - 15:30 | ទស្សនាចំការបន្លែរបស់ក្រុមកសិករ | ភូមិតាស្អាង ឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ | |
| 15:30 – 17:00 | ទស្សនាសិប្បកម្មផលិតអំបោសរបស់ក្រុមកសិករ | ភូមិឬស្សីព្រៃ ឃុំ កំពង់ចំឡង | មន្ទីរកិច្ចការនារី |

កម្មវិធីនេះអាចកែប្រែក្នុងករណីចាំបាច់ ។

សូមអរគុណ!